

# នៅពេល ស៊ូ គិត

Hyeli Ju

Rina Yoo

Let's Read

The Asia Foundation



កាដូដ៏មានតម្លៃបំផុតរបស់ស៊ូ គឺជាប្រអប់ខ្មៅដៃពណ៌ដែលលោកតារបស់គាត់បានឱ្យគាត់ ។ គាត់បង្កើតពិភពពណ៌ស្រស់ឆើតឆាយនៅក្នុងផ្ទាំងគំនូររបស់គាត់ជារៀងរាល់ថ្ងៃ ។



ថ្ងៃនេះ ស៊ូដើរទៅសាលារៀនលឿនជាងថ្ងៃធម្មតា ដោយសារតែ ថ្ងៃនេះគឺជាថ្ងៃដែល ស៊ូ បានប្រើខ្មៅដៃពណ៌ដ៏មានតម្លៃរបស់ គាត់។



ស៊ូបានគិតថា ”ស្លឹកឈើនៅរដូវក្ដៅមានពណ៌បៃតងស្រាល រីឯ
ស្លឹកឈើនៅរដូវស្លឹកឈើជ្រុះវិញ មានពណ៌ត្នោតស្រាល។”



"មិនថាស្លឹកឈើមានពណ៌អ្វី វាក៏នៅតែស្អាត។"



ដល់ម៉ោងមុខវិជ្ជាសិល្បៈហើយ!
ស៊ូរំភើបចិត្តណាស! ស៊ូយកចិត្តទុកដាក់ស្ដាប់អ្នកគ្រូសិល្បៈនូវអ្វីដែលអ្នកគ្រូនិយាយ។
"ថ្ងៃនេះយើងនឹងគូររូបពិសេសមួយ។ " ហើយគាត់ក៏សួរទៅកាន់សិស្សក្នុងថ្នាក់ថា "តើប្អូនៗចង់ដឹងទេថា មិត្តរបស់ប្អូននឹងគូរមុខរបស់ប្អូនបែបណា?"



អ្នកគ្រូបាននិយាយថា "ចូរប្អូនៗទាំងអស់គ្នាមើលទៅមុខរបស់មិត្តភក្តិប្អូនៗ។ ដំបូងយើងគូររូបភ្នែកទាំងពីរសិន។"
ស៊ូ និងមិត្តភក្តិចាប់ផ្តើមគូររូបភ្នែក ច្រមុះ បបូរមាត់ និងត្រចៀកគ្នាទៅវិញទៅមកនៅក្នុងក្រដាសរៀងៗខ្លួន។
មួយសន្ទុះក្រោយមក អ្នកគ្រូបានឱ្យសិស្សចាប់ផ្តើមផាត់ពណ៌ទៅលើគំនូរនោះ។
សិស្សទាំងអស់ក៏ជ្រើសរើសយកពណ៌ដូចគ្នាមកផាត់លើរូបគំនូរ។



ស៊ូ មើលទៅដៃគូរបស់គាត់ឈ្មោះ ចន ហើយគាត់ឆ្ងល់ថា តើចននឹងផាត់ពណ៌អ្វី។

"ចនមើលទៅហាក់ដូចជាកំពុងតែគិត ។ ប្រហែលជាចន ក៏កំពុងតែគិតដូចខ្ញុំដែរហើយ" ស៊ូគិត ។



ចនសម្លឹងមើលរូបគំនូររបស់ខ្លួន។

"ចន! តើឯងចង់ស្តាប់រឿងនិទានខ្មៅដៃពណ៌ ដែលលោករបស់ខ្ញុំនិទានប្រាប់ខ្ញុំទេ?" ស៊ូសួរ។

ចនងក់ក្បាល។



"កាលពីដើមឡើយ គ្រប់គ្នាហៅពណ៌នេះថា ពណ៌សស្លេក មិនមែនពណ៌សាច់នោះទេ" ស៊ូនិយាយ។

"ពណ៌សស្លេក?" ចនសួរ។

"មែនហើយ ពណ៌សស្លេក! ប៉ុន្តែដូចដែលឯងដឹងហើយថា មនុស្សគ្រប់រូបមានពណ៌ស្បែកមិនដូចគ្នាទេ មែនទេ? ដូចគ្នាទៅនឹងផ្កាកុលាប ដែលអាចមានពណ៌ លឿង ក្រហម ផ្កាឈូក ឬក៏ពណ៌សដែរ។"




"ដូច្នេះហើយបានជាគេប្ដូរមកហៅពណ៌នេះថាពណ៌សាច់វិញ"
ហើយប្អូនៗដឹងទេថា អ្នកទាមទារឱ្យផ្លាស់ប្ដូរឈ្មោះគឺជាក្មេងៗ
ដូចប្អូនៗ" អ្នកគ្រូប្រាប់។
"ប្អូនៗក៏អាចសម្រេចលទ្ធផលជាច្រើនរឿង ដូចក្មេងៗក្លាហាន
ទាំងនោះដែរ។ តោះប្អូនៗ យើងនាំគ្នាលើកទឹកចិត្តគ្នា និងផាត់
រូបគំនូររបស់ពួកយើង!"



ស្តាប់អ្នកគ្រូហើយ ស៊ូ និង ចន ក៏ញញឹម ហើយបន្ទាប់មក ស៊ូ
គាត់ក៏នឹកឃើញគំនិតមួយ។



”នៅរដូវក្តៅ មុខរបស់ខ្ញុំគឺបែបនេះ...” ស៊ូគិតហើយ ក៏ហុចខ្មៅដៃពណ៌ត្នោតមួយទៅឲ្យ ចន។

”ស៊ូ! ខ្ញុំគិតថាមុខរបស់ឯងមិនមែនពណ៌នេះទេ។” ចនឆ្លើយតប។

”ពណ៌នេះគឺត្រូវហើយ! មុខរបស់ខ្ញុំមានពណ៌បែបនេះបន្ទាប់ពីខ្ញុំត្រលប់មកពីលេងទឹកសមុទ្រនារដូវក្តៅវិញ!” ស៊ូបានបញ្ជាក់។



បន្ទាប់មកចនក៏ហុចខ្មៅដៃពណ៌ក្រហមឲ្យរូមី។
"ខ្ញុំចង់ឱ្យឯងផាត់មុខខ្ញុំពណ៌ក្រហម។ មុខខ្ញុំក្រហមនៅពេលដែលខ្ញុំឈ្លោះគ្នាជាមួយប្អូនប្រុសរបស់ខ្ញុំម្ដងៗ"។
រូមីក៏ខ្សឹបប្រាប់ទៅវិញថា "មុខរបស់ខ្ញុំប្រែជាពណ៌ផ្កាឈូកនៅពេលដែលខ្ញុំគិតដល់ស៊ូ។ ខ្ញុំពិតជាចូលចិត្តគាត់ខ្លាំងណាស់។" សិស្សទាំង៦នាក់បានបញ្ចប់ការគូររូបរបស់ពួកគេ។



ស៊ូដើរត្រលប់ទៅផ្ទះ ដោយដៃរបស់គាត់កំពុងកាន់រូបគំនូរ ”មុខរបស់ស៊ូ” ដែលមិត្តរបស់គាត់បានគូរឲ្យនោះយ៉ាងណែន។ ស៊ូសម្រេចចិត្តថា គាត់នឹងទុករូបគំនូរទាំងនោះនៅកន្លែងណាមួយដែលគ្រប់គ្នាអាចមើលឃើញ។






ឥទ្ធិពលរបស់កុមារ!



នេះជារូបរបស់អ្នកគ្រូដែលសិស្សរបស់គាត់បានគូរ។



”កុមារដូចជាពួកយើងមានសមត្ថភាពផ្លាស់ប្តូរពិភពលោកបាន!
”



សៀវភៅនេះផ្អែកទៅលើរឿងពិតមួយដែលបានកើតឡើងនៅ
ប្រទេសកូរ៉េខាងត្បូងក្នុងឆ្នាំ២០០១និង២០០៤។
រូបខាងឆ្វេង គឺជាជនបរទេសដែលជាអ្នកមានគំនិតក្នុងការផ្លាស់
ឈ្មោះរបស់ពណ៌និងជីតារបស់ស៊ូ ដែលបានចូលរួមក្នុងការ
ផ្លាស់ឈ្មោះនេះ។
រូបខាងស្តាំ ជារូបរបស់ ស៊ូ និងគ្រួសាររបស់គាត់។



រូបភាពក្នុងស៊ុមមួយនេះថតនៅឆ្នាំ ២០០៤ នៅពេលដែល
អ្នកគ្រូរបស់ស៊ូ និងសិស្សរបស់គាត់ទាមទារឲ្យផ្លាស់ប្តូរឈ្មោះ
ពីពណ៌ទឹកក្រូចស្រាល មកជាពណ៌សាច់វិញ។

BOOKS
INTERNATIONAL

អានសៀវភៅថ្ងៃនេះ ដើម្បីក្តីស្រមៃនៅថ្ងៃស្អែក ! សៀវភៅអន្តរជាតិគឺជាអង្គការក្រៅរដ្ឋាភិបាលដែលមានឯកទេសខាងសៀវភៅគំនូរ ។ យើងនិពន្ធ គូររូប និងចែកចាយសៀវភៅគំនូរទៅដល់កុមារដើម្បីអានជាភាសាកំណើតរបស់ពួកគេ។ ចក្ខុវិស័យរបស់ពួកយើងចំពោះអង្គការនេះ គឺផ្តល់ក្តីសុបិនដល់កុមារនាពេលអនាគត។ រឿងរបស់យើងក៏អប់រំកុមារអំពីបញ្ហាជីវិតពិត និងស្ថានភាពបច្ចុប្បន្ន។ សៀវភៅអន្តរជាតិមានគោលបំណងចង់ទទួលបានសមភាពសម្រាប់កុមារទាំងអស់ដើម្បីទទួលបានការអប់រំប្រកបដោយគុណភាព។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*When Soo Thinks*, Author: Hyeli Ju. Illustrator: Rina Yoo. Published by Books International, © Books International.

Translations: © The Asia Foundation, 2020.